# ការសម្ភាសរបស់ យ៉ុង កែវ

**ក៖ អ្នកសម្ភាសឈ្មោះ អេង ដាលីន** **ខ៖ អ្នកត្រូវគេសម្ភាសឈ្មោះ យ៉ុង កែវ**

ក៖ ជាដំបូងសូមជម្រាបសួរដល់បងស្រីដែលបងស្រីបានអនុញ្ញាតិអោយនាងខ្ញុំបានមកសម្ភាសបង ដែលទាក់ទងពីប្រវត្តិរបស់បងក៏ដូចជាទាក់ទងពីប្រវត្តិប្រជាជនខ្មែរ ដើម្បីអើ... ប្រវត្តិមួយនេះទុកអោយកូនចៅបងជំនាន់ក្រោយបានស្តាប់ បានដឹងពីប្រវត្តិបងស្រីហាសណាំបង។ បងអើ... ខ្ញុំឈ្មោះអេងដាលីនហើយខ្ញុំដែលជាអ្នកសម្ភាសបង ហើយខ្ញុំមក ខ្ញុំតំណាងអោយសាកលវិទ្យាល័យមួយដែលនៅអាមេរិចដែលមានឈ្មោះថា BYU ហើយថ្ងៃខែដែលខ្ញុំសម្ភាសបងគឺនៅថ្ងៃទី២៦ខែ៨ ២០១៨។ ចាំ! បងអើ...បងព្រមអនុញ្ញាតិអោយរូបនាងខ្ញុំសម្ភាសបងទេបង?

ខ៖ សម្ភាសទៅសម្ភាសបាន។

ក៖ ចាំ! អរគុណ! បងចាំអើ...បងៗនៅភូមិនេះភូមិអីដែរបង?

ខ៖ ភូមិថ្នល់ ឃុំស្រង៉ែ។

ក៖ ស្រុក?

ខ៖ ស្រុកសៀមរាប ខេត្តសៀមរាប។

ក៖ ចាំបង! បងមានឈ្មោះពេញមានឈ្មោះអីដែរបង?

ខ៖ ឈ្មោះយ៉ុង កែវ។

ក៖ យ៉ុង កែវ?

ខ៖ ចាំ!

ក៖ ឈ្មោះពេញ អូ! រៀងខ្យល់តិច! ហើយអត់អីទេ បងចឹងបងមានឈ្មោះហៅក្រៅទេបង?

ខ៖ អត់មានទេមានឈ្មោះតែមួយហ្នឹង។

កៈ មានឈ្មោះតែមួយហ្នឹងណោះបងណោះ?

ខៈ ចាំ!

កៈ ចាំ! ហើយចុះបងអើបងឥឡូវរាល់ថ្ងៃមានអាយុប៉ុន្មានឆ្នាំហើយបង?

ខៈ ៣៨!

កៈ ៣៨?

ខៈ ចាំ!

កៈ ហើយចុះបងឆ្នាំច័ន្ទគតិ ឆ្នាំជូត ឆ្លូវ ខាល ថោះបងឆ្នាំអីបង?

ខៈ ឆ្នាំច!

កៈ ឆ្នាំច ចាំ!

ខៈ ឆ្នាំច កើត៨២ (១៩៨២)។

កៈ កើតឆ្នាំ១៩៨២?

ខៈ ចាំ!

កៈ បងអើទីកន្លែងកំណើតបងកើតនៅណាដែរបង?

ខៈ កើតនៅខេត្តបាត់ដំបង។

កៈ បាត់ដំបង?

ខៈ នៅស្រុកបវិល។

កៈ ស្រុកបវិល?

ខៈ ចាំ!

កៈ ខេត្តបាត់ដំបង! អូ! អ្នកបាត់ដំបងណោះបងណោះ?

ខ៖ ចាំ!

ក៖ ចាំ!

ខ៖ តែយើងកូនកំព្រាហោស។

ក៖ ចឹងហោសបង!

ខ៖ កូនកំព្រាមកនៅជួយមីង។

ក៖ ចាំបង! បងមានបងប្អូនប៉ុន្មាននាក់បង?

ខ៖ បងប្អូន៤នាក់។ សុទ្ធតែស្រី បងប្អូន៤នាក់ហាសស្រី។

ក៖ ចឹងអើបងជាកូនទីប៉ុន្មានដែរ?

ខ៖ កូនទី២។

ក៖ ទី២?

ខ៖ ចាំ!

ក៖ ចឹងបងអាចរៀបរាប់ឈ្មោះបងប្អូនបងបានទេបង?

ខ៖ ឈ្មោះអើ...ឈ្មោះយ៉ុងជាតិ មួយ យ៉ុងសុគន្ធ មួយ ហើយមួយទៀតនោះ ប្អូន ប៉ុន្តែអោយគេកាលនៅកូនង៉ា។ គេស្លាប់ចោលតាំងពីនៅតូចតែអោយគេ អាយុ៨ខែយើងនៅក្មេងដែលកាលណុង។

ក៖ បងអាយុប៉ុន្មានឆ្នាំ?

ខ៖ កាលនោះប្រហែលជាប្រាំបីប្រាំបួនឆ្នាំនោះឯង បើមីទី៣នៅប៉ុននេះហោស មីទី៣នៅប្រហែលជា៩ឆ្នាំ អឹម...អឺ...ប៉ុននេះប្រហែលជាប៉ុន្មានឆ្នាំ? ប៉ុននេះឯងប្រហែលជាបីបួនឆ្នាំទេ។

ក៖ អូ៎! ម្តាយឪពុកបងស្លាប់ចោលណោះបង?

ខ៖ ចាំ!

កៈ ចាំ! ហើយចឹងបងអាចរៀបរាប់ឈ្មោះបងប្អូនបងបានទេបង?

ខៈ បានតើឈ្មោះមួយទៀតនោះឈ្មោះគឹម ឃឿន តែអត់បាននៅស្រុកនេះជុំគ្នាទេ មកនៅនេះមកនៅ តែបីនាក់ទេ ម្នាក់នោះបានប្តីនៅនោះ យើងអោយគេហើយ។ ម៉ែឪគេចិញ្ចឹមដល់ពេលបានប្តីទៅគេទៅ នៅរកស៊ីថៃ។

កៈ ចុះបងពីកាលក្មេងៗបងមានចាំសាច់រឿងថាសប្បាយជាមួយគ្នាពេលណា? ហើយពិបាកពេលណាទេ? បងអាចចាំបានអាចរៀបរាប់បានទេ?

ខៈ ចាំបានតើអាចរៀបរាប់បានតើអើ...

កៈ កាលនៅក្មេងៗបងតែងតែធ្វើអី?

ខៈ នៅក្មេងគឺបងនៅជុំគេអើនៅទីណោះតិចនៅទីនោះតិច ដូចវាអត់មានទីដៅពិតប្រាកដណោះ បើបងៗមួយទៀតហើយនិងមីប្អូនគេនៅកន្លែងនែំនៅជាមួយចិនហោសនៅ ជាមួយមីងមួយទៀត មីងមួយទៀតគាត់ចិញ្ចឹមមីងនោះពៅគេបង្អស់ហោស ទៅគាត់ចិញ្ចឹមទៅតែមិនដឹងថារកស៊ីអីចិញ្ចឹមក្មួយ គាត់ក៏នៅស៊ីឈ្នួលលាងចានគុយទាវអោយគេ ដល់ស៊ីឈ្នួលលាងចានគុយទាវអោយគេទៅ ពីរនាក់បងអូ!ប្អូន បងមួយហើយនិងបងមួយទៀត បងជាតិ ហើយនិងយ៉ុង សុគន្ធនោះ គេនៅជុំគ្នារហូត តែចំណែកបងវិញគឺ នៅទីណោះតិចនៅទីនេះតិច ដូចវាអត់មានអនាគតដូចយើង បើយើងជីវិតកូនកំព្រាថាដូចជារសាត់ អណ្តែតណាំ។ ដល់ពេលតាយាយគាត់គេជម្លៀសមកពីជម្រុំហោស អាជម្រុំសម័យហោស ដល់ពេលគេជម្លៀសមកក៏ទៅនៅជាមួយយាយទៅ ដល់ពេលអាចេញពីយាយមកវិញក៏មកនៅជុំមីងៗដែលពៅគេថានៅជាមួយចិននោះ លាងចានគុយទាវហោស។ ដល់ពេលមកដល់ហើយក៏គេនែំ!គេបានប្តី ដល់គាត់ឈប់នៅជាមួយអ្នកលាងចានគុយទាវទៅ គាត់បានប្តីក៏យកបងទៅនៅជាមួយ ពេលយកបងទៅនៅជាមួយបងក៏ធំហើយ១៣ឆ្នាំ ដល់ពេលបានអាយុ១៣ឆ្នាំ... ដល់បានអាយុ១៣ឆ្នាំហើយស្រាប់តែបងចេះច្រូតចេះអីបានហើយ ចេះធ្វើការអាចបានលុយខ្លះហើយណាំដល់ពេល...ដល់ពេលយើងទៅគិតតែអង្ករ មីងគាត់ប្រើអោយមកយកអង្ករហោស យើងស្រែរនាម(ឈ្មោះកន្លែង)ឆ្ងាយដែរ ហើយបងដើរម្នាក់ឯង ហើយសម័យនោះវាអត់មានអាគ្រឿងញៀនគ្រឿងអីទេ ហើយយើងក្មេងអាយុត្រឹម១៣ឆ្នាំ យើងអាចដើរបានណាំ។

កៈ ចាំ!

ខ៖ ហើយស្រូវអ្នកខេត្តបាត់ដំបងមែនទៅទាបៗឯណាមីអូន ហើយវាលិចៗក្បាលយើងបាត់ណាហើយ ស្វាត់អណ្ដេញ ហើយយើងដើរមានផ្លូវស្រួលអីណា ហើយទឹកត្រឹមៗនេះ ហើយស្ពាយសាក់កាដូ ហើយអង្ករ៥០កំប៉ុង វាធ្ងន់ដែរប៉ុណ្ណោះដល់ពេលតែដល់ពេលខែអាខែវស្សាផុតទៅខែច្រូត ចេញពីអាខែច្រូតមកពួកកាលនោះវាអត់ទាន់ចប់ទេ វានៅសង្គ្រាមដែរ ខែក្រហម ខ្មែរក្រហមយើងទាហានយើងហោស។ បងច្រូតប្រហែលពីនេះ បងមើលឃើញទាហានយើងហើយនិងខ្មែរក្រហមបាញ់គ្នាឮសូរគ្រាប់កាំភ្លើងប្រះព្រោះៗហោស ហើយយើងទៅច្រូតអីនេះទៅ មើលទៅខ្មែរក្រហមគេដុតនែ៎!នេះហ្មេស ដុតស្រូវដុតអី ប្រជាជនអស់ទៅក៏ឆេះភ្លើងឆេះអីនោះឯង ដល់ពេលទៅដល់នេះឡើងខំអីក៏បងមិនបានមកនៅនេះដែរ។មីងនៅនេះគាត់បានប្ដីនៅនេះទៅគាត់ទៅយកបងនៅនេះដែរ ដល់ពេលដែលយកយកមកក៏មីង នោះថាមីងអូនឯងទៅនៅជាមួយអីនោះសិនទៅចាំស្រុកស្រួលបួលម៉េចៗចាំមីងមកយកវិញ ថានោះ។

ក៖ ហើយចុះមីងចឹងឪពុកម្ដាយមីងឈ្មោះអីដែរមីង?

ខ៖ ឪពុកម្ដាយបងអើឈ្មោះ...

ក៖ អើបង!

ខ៖ ឈ្មោះនែ៎... ឈ្មោះយ៉ុង។

ក៖ ម្ដាយឈ្មោះយ៉ុង?

ខ៖ ឪនោះឈ្មោះយ៉ុង តែម៉ែនោះឈ្មោះ ថៃន។

ក៖ ឈ្មោះថៃន ចាំ!

ខ៖ ឈ្មោះថៃន។

ក៖ ពួកគាត់បើសិនជានៅរស់ប្រហែលជាអាយុប៉ុន្មានហើយមីង?

ខ៖ ព្រោះអីបើសិនជាគាត់នៅរស់ប្រហែលជាខ្ទង់ហាហើយហ្នឹងឯង។

ក៖ ចាំ! ចូលហា  ចាំ! ហើយចុះពួកគាត់អើ...ពេលមីងនៅតូចៗ ពួកគាត់រុះរានមានជីវិតដែរតើមែនទេ?

ខ៖ មានគាត់នៅ...

ក៖ ពេលណុង កាលដែលគាត់នៅរស់ហាស គាត់រកស៊ីអីចិញ្ចឹមកូនដែរបង?

ខ៖ បើកាលនោះយើងមានស្រែមានអីដែរ យើងនៅស្រុកនោះ វាមិនអត់ស្រែទេ ពុកគាត់ធ្វើស្រែទៅ ម៉ែ ពេលអាខែយើងធ្វើស្រែ ធ្វើស្រែទៅណាំ អាពេលខែទំនេរ ពុកបងនោះ គាត់ពីជំនាន់មុននោះធ្វើស្មៀន ខាងស្មៀនខាងអីហាស ហើយគាត់ចេះឆ្លាក់រូបព្រះ រូបព្រះយើងធ្វើនែ៎... ចែមធ្វើហ្នឹងអីហាស ពេលណាគេត្រូវការអោយគាត់ឆ្លាក់ គាត់ក៏ឆ្លាក់អោយគេទៅហើយ គាត់ធ្វើមេខ្លាឃ្លោកធ្វើអី គាត់ធ្វើជាគ្រាប់អោយគេហាស គាត់មិនបានអ្នកលេងទេ ប៉ុនគាត់ធ្វើអោយគេទៅ...

ក៖ គាត់ពូកែហាសណាំបងណាំ!

ខ៖ គាត់សរសេរជាគំនូ សរសេរជាអី សរសេរជាដូចជាអក្សរគេត្រូវសរសេរដាក់ក្នុងក្រណាត់ចឹងទៅ គាត់សរសេរអោយគេហាសណាំ។

ក៖ ហើយអក្សរគាត់ស្អាតអត់បង?

ខ៖ អក្សរគាត់ស្អាតដែរ ប៉ុន្តែបងដូចតែវានៅក្មេងៗដែរ ដូចយើងចាំគាត់អត់បានហាស។

ក៖ ចាំគាត់អត់បាន។

ខ៖ ដល់ពេល...

ក៖ ចុះមូលហេតុអីបានគាត់ស្លាប់ទាំងពីរនាក់ចឹង?

ខ៖ អើសម័យនោះ បើភាគច្រើនគេថាអាម៉្យាងនោះឯង តែអត់មានជម្ងឺខ្លួនឯងទេ គាត់...

ក៖ គាត់ម៉េចវិញ? បងអាចរៀបរាប់បានទេបង?

ខ៖ រៀបរាប់បាន ហើយពីមីងដែលនៅក្រមុំនោះ គាត់និយាយថានិយាយរឿងទៅ ថានិយាយហើយមីងនៅក្រមុំនោះគាត់ទៅច្រូតស្រូវ អើ... ទៅច្រូតស្បូវ អាស្បូវយើងគេយកមកក្រងបាំងដំបូលនោះ។

ក៖ ហ្នឹងហើយបង!

ខ៖ ទៅសុំគេដោយសារ គេមានរទេះ យើងអត់មានរទេះ ទៅសុំដោយសារនឹងគេទៅច្រូត ពេលទៅច្រូត ហើយសម័យស្រុកនោះ...សម័យស្រុកនោះអោយតែហ៊ានចាប់ដៃចាប់អាវចេះ ដឹងតែគេប្រកាន់ហើយ ព្រោះអីយើងក្រមុំហោស តែខំខ្មោចសុំស៊ីហើយ ដល់អាអ្នកដែលចាប់ នោះគេមានប្រពន្ធហើយ បងចាំបានហាស គេមានប្រពន្ធហើយដល់ពេលល្ងាចឡើងមកផ្ទះក៏ មានការប្តឹងផ្តល់គ្នា ឈ្លោះគ្នា គេអត់ទទួលខុសត្រូវហាស អាអ្នកដែលមានប្រពន្ធហ្នឹងណាំ ដល់ពេលប្តឹងផ្តល់គ្នាទៅ ដឹងមូលហេតុទៅជាស្អីទេក៏ចប់ទៅជាបងដឹង តែត្រឹមតែឈ្លោះគ្នា ប៉ុណ្ណឹងឯងដល់ពេល...

ក៖ ពេលហ្នឹងឪពុកបងហោស?

ខ៖ ឪពុកបងក៏គាត់មិនសូវចេះនិយាយទេ។

ក៖ អូ៎! ចឹងហោស!

ខ៖ ចាំ! គាត់មិនសូវចេះនិយាយទេ។

ក៖ ចាំ! ចឹងមើលទៅគាត់ស្លាប់ទៅ?

ខ៖ គាត់...

ក៖ អត់មានជម្ងឺអីទេហោសបង?

ខ៖ ឈឺ! គាត់ឈឺ ចាំមើលហាស មើលបងនិយាយហាស ឈឺអារបៀបយើងក្តៅក្នុងដើមទ្រូង ក្តៅ បើម៉ែបងវិញ គាត់ដេកអោបតែពាងទឹកទេ ក្តៅខ្លាំងពេកណាស់ ហើយគាត់ក៏ពេលស្វាង ចេស ពេលឪស្វាងម្តង ធូន់ម៉ែ ពេលម៉ែនែ៎ស្វាងធូន់ឪ ម្នាក់ម្តងៗ។

ក៖ ចឹង? ឈឺរហូតចឹង?

ខ៖ ឈឺរយៈពេលតែមួយអាទិត្យទេ ដែលឈឺប្រណាំងគ្នាហ្នឹងហាស រយៈពេលតែមួយអាទិត្យ ទេ។

ក៖ រួចទៅស្លាប់ទាំងពីរ?

ខ៖ ស្លាប់ទាំងពីរ! ចាំមើល...

កៈ ពេលរួមគ្នាមែនបង?

ខៈ អត់ទេ! ចាំមើលហាស ចាំមើលបងនិយាយហាស ដល់ពេលមើលគាត់ធ្ងន់ខ្លាំងពេក ផ្ទះនៅឆ្ងាយពីផ្ទះយាយហោស ដល់ពេលនេះឡើង ម៉ែរៀងខ្លាំងគេក៏សែងម៉ែនៅអជ្រឹងមកផ្ទះយាយព្យាបាលផ្ទះយាយ ដល់ពេលរកគ្រូមើលទៅអីទៅ គាត់អត់ជាទេ ថ្ងៃដែលម៉ែស្លាប់នោះ ពុកនោះគាត់ក៏អង្គុយមុខជណ្ដើរ គាត់អត់ទាន់អីទេ។ មនុស្សយើងជាធម្មតា អង្គុយដូចយើងអត់មានឈឺអីទេ ថាៈ « បើសិនតែម៉ែកូនឯងស្លាប់ទៅពុកក៏ទៅដែរកូន។ » ថាចេះ គាត់និយាយហាស ដល់ពេលធ្វើបុណ្យម៉ែរួច រយៈពេលបានបីថ្ងៃ ឪស្លាប់ម្ដង មួយទៀត។

កៈ ពេលណុងជីវិតពិបាកខ្លាំងអត់មានម្ដាយអត់មានឪពុកចឹងហាស?

ខៈ ពិបាក! ពិបាកខ្លាំងហាស ព្រោះអីយើងកូនកំព្រាមិនដឹងពឹងនរណាណាស់ ទៅយើងក៏មិនដឹងទៅធ្វើម៉េច។

កៈ ចាំ! ហ្នឹងហើយបង។

ខៈ និយាយរឿងជីវិតពិត។

កៈ ចាំ! បងចឹងដល់ពេល... អូ! ខ្ញុំគ្រាន់ស្ដាប់ប្រវត្តិបងចឹងហាសណាស់ ជូរចត់ចឹងហាសបង ហើយចុះបង បងមានដឹងថាអើឪពុកម្ដាយបងអ្នកស្រុកណាទេបង?

ខៈ ឪពុកម្ដាយបងគឺអ្នកស្រុកនៅនឹងខេត្តនេះ! បាត់ដំបង ស្រុកបវរិលហ្នឹងឯង។

កៈ ស្រុកបវរិលហ្នឹងហោស?

ខៈ នៅភូមិស្រណាល។

កៈ ចឹងហោសបង។ ចាំ! ហើយបងរៀបការតាំងពីឆ្នាំណាដែរបង?

ខៈ បងអត់បានរៀបការទេ តែបងបានកូនម៉ែនេះសែនធម្មតាទេ កាលអាយុឆ្នាំអើ កាលនោះបងបាន២១ហើយ។

កៈ ឆ្នាំណាដែរបង?

ខៈ ឆ្នាំអើ២០០១។

ក៖ អ៊ូ! ចឹង?

ខ៖ ចាំ!

ក៖ ដូចថាស្រឡាញ់គ្នាដោយចិត្តនឹងចិត្តណោះបងណោះ?

ខ៖ ស្រឡាញ់គ្នាចិត្តនឹងចិត្ត។

ក៖ ហើយប្រាប់ឪពុកម្ដាយ?

ខ៖ ឪពុកម្ដាយក៏គាត់ស្រឡាញ់ គិតទៅក៏គាត់ឃើញនែ៎! បងតាំងពីក្មេង ចុះបងនៅជុំមីង បើថាពិបាកពីនោះ ហើយដល់មកនៅជុំមីងពិបាកមួយសារទៀត។ បងរែកបង្អែមលក់រែកមួយចានមួយរយមីអូន កាលនោះណាំ មួយចានមួយរយ អត់ទេ។

ក៖ អើបានអីផ្សេងដែរ!

ខ៖ នែ៎! រែកលក់ព្រឹកឡើងចេះ ក្រោកធ្វើឡុត រួចអីរួច រែកមកហើយ រែកពីផ្ទះ កាលនោះផ្ទះបងនៅអីកើតទេ។ ភូមិថ្នល់ដូចគ្នា តែនៅម្ខាងម្នាក់ រែកមកដល់ក៏អង្គុយៗតែផ្ទះម៉ែនេះឯង ទៅឪក្មេកហៅតែកូន   ប្រសារៗ ហៅរហូត ដល់ពេលមកក៏ជួយធ្វើជាលគាត់ ហូបបាយហូបអីរួចដឹងតែទៅផ្ទះហើយដឹងតែលក់បង្អែមអស់ ទៅវិញហើយ។ ដូរអង្ករគេ ៨ចានបានអង្ករមួយគីឡូកាលនោះហាស ព្រោះអីអង្ករកាលនោះមួយគីឡូតែ៨រយទេ ហើយយើងលក់បង្អែមក្នុងមួយថ្ងៃបានតែប្រាំមួយពាន់ទេ ហើយយើងចិញ្ចឹមមីង កូនគាត់ប្រាំ ហើយប្ដីគាត់ជួយរកត្រីរកអីដែរដល់ពេលតែ...

ក៖ ចុះមីងបងអត់ជួយលក់បង្អែមទេ?

ខ៖ កាលដែលបងមិនទាន់មក គាត់រែកខ្លួនគាត់ ដល់ពេលដែលបងមកហើយ បងអ្នករែកម្ដង។

ក៖ ហើយចុះគាត់ ?

ខ៖ គាត់មុនដំបូងដែលយើងអត់ទាន់ស្គាល់អ្នកស្រុកនេះ ដែលយើងមកដល់ថ្មីហោស គាត់បណ្ដើរយើង យើងក៏រែកទៅ គាត់ក៏ដើរតាមពីក្រោយហោស។ កាលនោះបងទើបអាយុ១៣ឆ្នាំ

ជាងទេណាស់ ដែលបងមកពីនោះហោស ដល់ពេលតែគ្រាន់តែបងអាយុបានតែ១៧ឆ្នាំ បានបងធ្វើការសំណង់។

កៈ ធ្វើនៅណាដែរបង?

ខៈ កាលនោះអើ...ធ្វើ...ចាប់ផ្ដើមធ្វើបង្អស់នៅ...នែ់! ភូមិវប្បធម៌យើង កាលនោះអត់ទាន់មានទេណាស់ មីងអូនភូមិវប្បធម៌ អត់ទាន់មានទេ តែជាប់នឹងភូមិវប្បធម៌ សណ្ឋាគារគេសង់ថ្មីនោះ កាលនោះគេធ្វើជា មន្ទីរពេទ្យភូមិភាគ៥។ ភូមិភាគ៥នោះគឺមន្ទីរពេទ្យគេធ្វើអោយទាហ៊ាននៅហាស ទាហ៊ានព្យាបាលហាស បងធ្វើតាំងពីឆ្នាំនោះរហូត ធ្វើដល់អើធ្វើឡើងបីបួនឆ្នាំជាប់បានបងបាន...

កៈ បងពិបាកទេនៅពេលធ្វើសំណង់ចឹង?

ខៈ ពិបាកណាស់ ហើយធូន់ យើងធ្វើការងារធ្ងន់ៗ ហើយគេជេរ គេជេរសុទ្ធតែម្ដាយ តែបងទ្រាំព្រោះអីបងថាបងល្ងង់  អត់ចេះអក្សរហាស ព្រោះយើងអត់បានរៀន...

កៈ អត់បានរៀន អត់បានអីទាំងអស់?

ខៈ អត់បានរៀនទេ អត់បានរៀនក៏...ដល់ពេលយើងអត់ចេះអក្សរចឹង គេចេះតែជេរយើងហើយ ថាយើង យើងដើម្បីទ្រាំដើម្បី ថាក្នុងម៉ា...

កៈ ពេលណុងបងរៀបការហើយហីពេលណុង?

ខៈ កាលណុងអត់ទាន់បានប្ដីទេ កាលនោះនៅក្រមុំទេ។

កៈ ពេលណុងធ្វើសំណង់ហើយធ្វើអីទៀតបង?

ខៈ ធ្វើសំណង់តែមួយមុខ។ កាលនោះយើង អាមុនធ្វើសំណង់យើងស៊ីឈ្នួលស្លងគេ មួយថ្ងៃពីរពាន់ប្រាំកាលនោះ។

កៈ ស្លង...

ខៈ ដូរអង្ករ!

កៈ ធ្វើការគ្រប់អស់ហើយបង?

ខ៖ ធ្វើ...នៅតើធ្វើការតាមសណ្ឋាគារ រៀបបន្ទប់អីបងបានធ្វើហើយ នៅតែអាខាងលាងចាន លាងផ្ទាំង អោយគេនេះអត់ទាន់មានទេ ប៉ុន្តែដល់ពេលយើងបានប្តីនិយាយថានិយាយកាត់ៗ ទៅអោយវាឆាប់ចប់ ដល់ពេលបានប្តីហើយ កាលដែលបានមិនទាន់បានប្តីថាយើងពិបាកនៅជុំមីងហើយយើងពិបាកចិត្ត។

ក៖ ហើយចុះមីង ហើយចុះបងអើចុះនៅពេលដែលជុំមីងហាស មីងស្រឡាញ់យើងដែរ ឬមួយក៏ម៉េចដែរបង?

ខ៖ មីងស្រឡាញ់យើង ប៉ុន្តែគាត់តាមប្តីគាត់ ដល់ពេល...

ក៖ ប្តីអត់ស្រឡាញ់បងមែនបង?

ខ៖ ប្តីគាត់និយាយ អាររបៀបរៀងមើលងាយយើង របៀបថាពេលគាត់ពេលយើងមកពីធ្វើការវិញចេះយើង មកដល់ផ្ទះចេះគាត់មើលងាយសុទ្ធតែថាទៅធ្វើការនេះសុទ្ធតែមានប្រុស មានសាហាយហើយ បានមិនឃើញបើកលុយ ចឹងកាលណោះប្រាក់ក្នុងមួយខែបានតែ១២ម៉ឺនទេ។

ក៖ ហើយចុះបើកទុកខ្លួនឯងក៏អោយមីង?

ខ៖ អោយគេអស់ៗ មិនឮថាទេហាស ចង់ស្អាតនឹងគេ អ្នកមីងអើយអោយខ្ញុំបួនពាន់មក បួនពាន់ខ្មែរណាំអត់អោយយើងទេ  សុខចិត្តបោសលុយអោយយើងវិញថា ឆ្អែត ឆ្អែតមែន។

ក៖ អ៎ូចឹង! ចឹងធ្វើការអត់យកខ្លួនឯងទេ អោយមីងទាំងអស់?

ខ៖ អត់!

ក៖ អ៎ូ!មកពីយើងនៅជាមួយគាត់នោះបង?

ខ៖ នៅជាមួយគាត់ ហើយយើងក្មេងផង យើងមិនដឹងថាទៅពឹងអ្នកណា ព្រោះអីយើងអត់ស្គាល់គេណាំ ព្រោះអីនែ៎! យើងអត់ស្គាល់គេហើយ មិនដូចក្មេងសម័យនេះទេ ក្មេងសម័យនេះយើងវាអាចទៅនែ៎! ជួល ផ្ទះតាមបន្ទប់អី ជួលបាននៅហាស ចំណែកយើង...

ក៖ យើងអត់ដឹង។

ខ៖ យើងអត់ដឹង យើងទៅអត់រួច ព្រោះអី...

កៈ យើងពិបាកខ្លាំងពេលនៅជាមួយម្ដាយមីង?

ខៈ  ពិបាក! ពិបាកចិត្តត្រង់ថាពេលយើងមកដល់ គេជេរយើង បន្ទោសយើង តែមីងគាត់មិនជេរទេ តែប្ដីគាត់ផឹកទៅ គាត់ជេរយើងមើលងាយយើងហាស មើលងាយយើងសព្វគ្រប់ម៉ងហាស ដល់ពេលបងទ្រាំអត់បាន គាត់ថាយើងសន្សំប្រាក់បានទៅនែ៎! ទៅរត់តាមប្រុសហើយបានវាមិនបើកលុយបើកអី ដល់ពេលនេះមកទៅថា៖ « មករកត្រីជាមួយអញ ទៅដេករកត្រីជាមួយអញ។ » ចុះបងឮតែចុះ បងក្មេង ចេះតែខ្លាចហើយណាំ បងក៏រត់ចេញពីផ្ទះ។ ដល់ពេលដែលបងរត់ចេញពីផ្ទះទៅ រត់ចេញបានបីថ្ងៃ កុំអីក៏បងប្អូនបងមិនបានមកនៅជុំគ្នាស្រុកនេះដែរ បងរត់ ដល់ពេលដែលបងមកពីស្រុក បានមី យ៉ុង សុគន្ធនោះមកជាមួយផង ដល់ពេលមកជាមួយ បងក៏... « អូនអើយ យើងថ្ងៃនេះរត់ចេញពីផ្ទះនេះហើយ បើមិនចុះទេ គេធ្វើបាបបងហើយ។ » អោបកប្អូន នេះដើរកាត់អាវាលត្រង់នេះឯង  ផ្ទះបងរើពីនោះមកនៅនេះហើយ។

កៈ ចាំ!

ខៈ ដល់ពេលដើរកាត់អានេះក៏... កាលនោះដែលមានភ្លើងអី ក៏ទាហានគេយាមនៅនេះឯង ប៉ូលីសគេយាមយប់ អាម៉ោង១២នោះ ថានរណាគេ? ខ្ញុំអត់ហ៊ានឆ្លើយទេ ដល់ពេលអត់ហ៊ានឆ្លើយក៏ដើរគេសួរហើយសួរទៀតបានដាច់ចិត្តថាឆ្លើយ « ខ្ញុំ! » « ទៅណា? ម៉េចបានសួរមិនឆ្លើយ។ » កាលនោះរៀងតឹងណាស់ អត់មានថាដើរចេញរហេតរហូតបានទេ ទៅក៏ខ្ញុំទៅផ្ទះអ៊ុំខ្ញុំខាងកើតនេះឯង ដល់ពេលតែគេក៏ឈប់សួរយើងទៅ។ យើងក៏ប្អូន...ថាបងចុះមានតែខោ ខោពីរជាន់អាវពីរជាន់ ប្រាក់គ្មានមួយរយខ្មែរទេ។

កៈ ហើយយើងបងទៅរស់នៅណាទៅបង?

ខៈ ទៅនៅអើទៅដល់ផ្ទះមេជាងទាំងយប់ ម៉ោងមួយ ម៉ោងមួយយប់បានទៅដល់ផ្ទះមេជាង ដល់ផ្ទះមេជាង គាត់បញ្ជូនបងទៅអង្គរជុំ ទុកប្អូនចោលនៅផ្ទះមេជាង ដល់ពេលទៅដល់អង្គរជុំ ហើយធ្វើការនោះបានពីរថ្ងៃ ធ្វើការបានពីរថ្ងៃដឹងដំណឹងថាបងនៅអង្គរជុំ គាត់ទៅតាមបងឯនោះ ទៅតាមឯនោះជួបគាត់នៅផ្សារអង្គរជុំដែរ តែបងអត់អោយឃើញមុខទេ។ បងគេចចេញ  ដល់ពេលបងជិះឡានមកដល់ឯស្វាយធំនេះ ល្ងាចម៉ោងបី គាត់រកបងឃើញនៅស្វាយធំ ការប្អូនមេជាងហាស ដើររកឃើញទៅក៏គាត់ថា៖ « ទៅផ្ទះយើងវិញទៅក្មួយ។ » មីងហាស យើងចិត្តអត់ដាច់ទេ ដំណាក់កាលនោះយើងចិត្តអត់ដាច់។ « បងប្អូនហៀងមកអស់ហើយ មក

នៅក្នុងផ្ទះអស់ហើយ ហៀងទៅវិញទៅ។ » អ្នកស្រុកនោះគេថា៖ « អើ! ក្មួយអើយ ទៅផ្ទះវិញទៅ កុំអោយមកនៅចេះ ដោយសារក្មួយ... »

ក៖ ដោយសារយើងម្នាក់ឯង!

ខ៖ យើងម្នាក់ឯង ហើយយើងតែលតោល ខុសត្រូវអីនិយាយប្រាប់មីងយើងទៅ គាត់និយាយចេះណាំ។

ក៖ ចាំ!

ខ៖ ដល់ បងប្អូនបងមកមិនទាន់ប៉ុន្មានផង បងហ្នឹងថាបងមករស់នៅជាមួយមីអូនឯងហើយ បងខ្ញុំបងបង្អស់ហាស ទៅគាត់ក៏ទៅស្រុក ទៅស្រុកដល់ពេលគាត់ទៅដល់ស្រុកទៅយកអង្ករយកអីមកពីស្រុក ថ្លៃស្រែ ដៃឡូកាលនោះស្រែអត់ទាន់លក់ទេ ស្រែពីរហាត្ថា ស្រែកេរ្តិ៍ខាងឪហោស គាត់អត់ទាន់បានលក់។ដល់ពេលយប់ដែល បងចេញទៅស្រុក គាត់ឯនេះស្លាប់ មាហាសណាស់។

ក៖ មាពូហោស?

ខ៖ នោះឯង មាដែលមើលងាយបងហាសណាស់។

ក៖ គាត់ស្លាប់?

ខ៖ អើ! គាត់អត់បានផឹកបានអីទេ អាថ្ងៃដែលគាត់ងាប់នោះ។ ព្រោះអីយើងអត់មានអីហូបសម័យនោះវា មានអាខ្យងស្រែយើង គាត់ដើរចាប់ខ្យងបានក៏ស្ងោរៗ បានក៏ធ្វើជ្រក់ក៏ដូសបាយបានកន្លែងគាត់ដេកនេះឯង។ បងគាត់ទៅធ្វើការបាត់ទៅ ដល់ពេលតែយប់ឡើងម៉ោងបួនទាបភ្លឺហោសគាត់ប្រកាច។

ក៖ ស្លាប់នឹងពុលខ្យងហ្នឹងទេដឹងបង?

ខ៖ អត់ទេ! បើខ្យងហូបបានទាំងអស់គ្នានោះ។

ក៖ អ៊ូចឹង!

ខ៖ អាថ្ងៃនោះ គាត់អត់ផឹកអត់អីទេ។ ងាប់ ដល់ពេលៗតែងាប់ហើយ មួយៗគេថាអើ! កែវអើយ កូនឯងផុតទុកផុតទោសហើយ គេថាណាស់ អ្នកស្រុកដែលគេដឹង គេស្រណោះខ្ញុំហោស ថាផុតទុកផុតទោសហើយកូនឯង ស្រាប់តែថាចុះឡើងមិនផុតទុកផុតទោសទេថាមីអូនអើយថាពិបាកជាងអាមុនទៅទៀត។

ក៖ ម៉េចចឹងបង?

ខ៖ រកស៊ីចិញ្ចឹមកូនគេ ចុះឪគេអត់នៅ ហើយរកស៊ីចិញ្ចឹមកូនគេ។

ក៖ ពេលណុងកូនគាត់តូចៗមែន?

ខ៖ កូនគាត់ត្រឹមអាយុអើ...ប្រាំបី ប្រាំបួនឆ្នាំ មានអាជាងដប់ឆ្នាំផង។ មីបងនោះដប់ពីរឆ្នាំ បើអាក្រោយៗគេនេះ កូន៥គិតទៅ អាក្រោយគេនោះប៉ុនអាកូនមីអូននោះដើរមិញ។

ក៖ រកស៊ីចិញ្ចឹមទាំងអស់?

ខ៖ រកស៊ីចិញ្ចឹមទាំងអស់ មិនឮថាទេហ្វេស។  អង្ករមួយប៉េបានតែមួយអាទិត្យទេ ឮបងទៅធ្វើការមកដល់ផ្ទះ ពីវត្តបូរណ៍ហាស មីអូនស្គាល់វត្តបូរណ៍អត់?

ក៖ ចាំ! ស្គាល់!

ខ៖ វត្តបូរណ៍ហាស បងធាក់កង់មក (ប្តីចាំបាយហើយលែងនិយាយរឿងប្រវត្តិ) មកពីនេំ! មកពីវត្តិបូរណ៍មកដល់ផ្ទះ ស្រាប់តែឃើញប្អូនទើបតែដើររកខ្ចីអង្ករគេមកដាំបាយ បងក៏ឆ្អែកចិត្ត ស្រាប់តែមកដល់អត់មានអីហូបហាស  ថា៖ « មីងអើយសុំលុយប្រាំរយមកមីង ខ្ញុំទិញនំហូបហើយ។ »

ក៖ ថាពិបាក...

ខ៖ ថាចេះទៀត...

ក៖ ចាំ! អូខេ ឥឡូវជីវិតបងជាមួយក្រុមគ្រួសារបងធូរជាងមុន ឬមួយក៏ម៉េចដែរ?

ខ៖ វាគិតទៅពីមុនមក វារៀងធូរតិចឯង ដែលប្តីនៅជាដល់ពេលសព្វថ្ងៃប្តីឈឺដែរ បងរៀងពិបាក។ ចាត់ទុកថាពិបាកបន្តិចទៅចុះ ចូលមកឆ្នាំនេះដឹងតែពិបាកហើយ កាលដែលប្តីនៅរកបាន

គាត់រត់ម៉ូតូឌុបរត់អីបានទៅ  បងទៅធ្វើការធ្វើអី ហើយបងធ្វើការកូនទម្ងន់ឡើង៥ខែ បានបងឈប់ធ្វើការសំណង់ណាស់ ដែលបានប្តីហើយណាស់ណុងឯង។

ក៖ ចាំ! ចុះបងអត់បានរៀនបានអីទេនោះបង?

ខ៖ អត់បានរៀន! មិនឮថារៀនអក្ខរកម្មបានបីយប់ គេថាបងនេះមានប្រុស ថាបងមានសាហាយ មានោះ ណាស់។

ក៖ ហ្នឹងហើយបង។ ចឹងដល់ពេលសប្បាយ ប៉ុល ពត បងកើតទាន់ទេបង?

ខ៖ បងកើតអត់ទាន់ទេ។ ប៉ុន្តែបងទាន់ត្រង់តែអាសង្គ្រាមចុងក្រោយបន្តិចហ្នឹងឯង ដល់ពេលបង...

ក៖ ពេលហ្នឹងបងអាយុប៉ុន្មានឆ្នាំដែរ?

ខ៖ អាកាលនោះបងអត់ចាំអាយុទេ។ កាលដែលនៅសង្គ្រាម ដែលរត់ចូលត្រង់សេត្រង់អីហ្នឹងបងអត់ចាំទេ។ បងចាំបានតែត្រង់ថា បងមកនេះអាយុ១៣ តែសង្គ្រាមវានៅមានខ្មែរក្រហមវាអត់ទាន់ដាច់ទេ។

ក៖ ចាំ! បងហើយចុះឥឡូវបងកាន់សាសនាអីដែររាល់ថ្ងៃ?

ខ៖ សាសនាព្រះពុទ្ធយើង។

ក៖ ព្រះពុទ្ធសាសនាយើង?

ខ៖ ចាំ!

ក៖ រាល់ថ្ងៃបងមានកូនប៉ុន្មាននាក់ដែរបង?

ខ៖ កូន៣នាក់។

ក៖ កូន៣នាក់!

ខ៖ ចាំ!

ក៖ ប្តីបងឈ្មោះអីដែរបង?

ខ៖ ឈ្មោះអើ... យ៉ាន យិន។

ក៖ យ៉ាន យិន?

ខ៖ ចាំ!

ក៖ ប្តីរបស់បងឈ្មោះ យ៉ាន យិន ?

ខ៖ ចាំ!

ក៖ គាត់មានអាយុប៉ុន្មានឆ្នាំដែរពល់ថ្ងៃ?

ខ៖ ប្តីហ្នឹងអាយុ៣៩។

ក៖ ចាំ !

ខ៖ គាត់អាយុបងបងមួយឆ្នាំ។

ក៖ ៣៩!

ខ៖ ចាំ!

ក៖  ហើយចុះបងមានចាំអើ... ឈ្មោះជីដូនជីតាខាងឪពុកទេបង?

ខ៖ ជីដូនជីតាឪពុកបងហោស?

ក៖ ចាំ! តាយាយខាងឪពុកខាងម្តាយហាស?

ខ៖ អើ! ស្គាល់តើ យាយនោះឈ្មោះ យាយ អ៊ុច តានោះឈ្មោះ តាជ្រូក ឈ្មោះគាត់ណាស់។

ក៖ ចាំ!

ខ៖ ដល់បើយាយខាងអើ...ម៉ែឈ្មោះ តា វ៉ែន ហើយយាយ ខាំ ឈ្មោះគាត់ណាស់។ បងចាំបានទាំងអស់ហើយបងទាន់តាទើបស្លាប់បានពីរឆ្នាំទេ បើយាយគាត់ខូចទាំងពីរយូរហើយអត់ឃើញមុខគាត់ទេបើស្គាល់តែ ឈ្មោះគេហៅ។

ក៖ តាយាយខាងឪពុក?

ខ៖ ខាងម្ដាយ បើខាងឪពុកបងទាន់ទាំងពីរ។

ក៖ ចាំ!

ខ៖ គាត់ស្លាប់អស់ហើយ។

ក៖ ហើយចុះរួចទៅបងឯងមានបងប្អូនរស់នៅខាងខេត្តផ្សេងទេបងប្អូនបង្កើតបងឯងហាស?

ខ៖ អត់មានទេ! មានតែមកនៅខេត្តនេះឯង មានបងប្អូនបួននាក់ បើមួយទៀតនៅស្រុកនៅគេទៅថៃហើយ ដែលថាអោយគេពីតូចនោះ។

ក៖ ចាំ! ហើយចុះគាត់ចាំបងប្អូនអីទាំងអស់តើហី?

ខ៖ ចាំបាន! ព្រោះអីគេ បងប្អូនខាងនោះ គេអត់លាក់ទេ។ គេប្រាប់បានទាំងអស់ប្រាប់អោយស្គាល់បងប្អូនមកលេងដែរតើ។ កាលពីឆ្នាំមុនមកលេង ដល់ពេលទៅថៃក៏មិនដែលបានទាក់ទងគ្នាទេ។

ក៖ បងចុះបងរាល់ថ្ងៃបងប្រកបមុខរបរអីដែរបង?

ខ៖ បងលើកមុនរាល់...អាស! រាល់ថ្ងៃនេះ?

ក៖ ចាំ!

ខ៖ បងលក់បង្អែមមុខផ្ទះនោះ សល់ពេលដែលលក់ទៅវាមិនដាច់ទេ ដូចថាទិញអស់ប្រាំម៉ឺនលក់បានបួនម៉ឺន ក៏បងមួយថ្ងៃជាមួយថ្ងៃក៏ថែមដើមរហូត មួយថ្ងៃថែមបន្តិចៗ ដល់អស់អាដើមថែមហ្នឹងទៅ បងគិតថាអើផ្អាកលក់ហើយ។

ក៖ ចាំបង!

ខ៖ ដល់ពេល...

ក៖ ចឹងជីវិតបងពិបាកខ្លាំងនោះបង?

ខ៖ ពិបាក! ដល់ពេលដែលប្អូនខាងនេះ នេះប្អូនគេលក់ចាប់ហ្វយនោះ ត្រូវនៃកូនជនល្លងម៉ែ ទៅគេឃើញគេស្រណោះ គេហៅអោយច្រកអេតចាយ គេអោយមួយថ្ងៃពីរម៉ឺនប្រាំដែរ។

កៈ អ៊ូ!

ខៈ វានៅជិតផ្ទះ។

កៈ គាត់អ្នកទិញអេតចាយហោស?

ខៈ គាត់ទិញអេតចាយផង គាត់លក់ចាប់ហួយផង។

កៈ ចាំបង! ចឹងបងជាចុងក្រោយបងមានពាក្យពេចន៍អីផ្តាំផ្ញើរដល់កូនចៅក្រោយអោយពួកគាត់ជៀសវៀងអីៗ?

ខៈ ហ្នឹងហើយ!

កៈ អោយពួកគាត់ខំប្រឹងចឹងហាសបង?

ខៈ កូនចៅជំនាន់ក្រោយ បើសិនថាអាចជៀសវៀង បានកុំអោយប្រព្រឹត្តអីខាងគ្រឿងញៀន កុំអោយប្រព្រឹត្តិ ធ្វើជាមនុស្សល្អ កុំអោយធ្វើជាក្មេងអាឡែលតែលអីណាស់។

កៈ ចាំបង!

ខៈ សុំតែប៉ុណ្ណោះឯង បើសិនតែចំណែកបងវិញ កូនរៀនដល់ពេល... កូនវាកើតមកវាឆ្លាតៗ វារៀនចេះហាស កូនបងហាសចំណែកតែ បងរកប្រាក់បានកូនរៀនទេ។

កៈ ចាំ! ចឹងអរគុណ!

ខៈ ចាំ!

កៈ ជាចុងក្រោយអរគុណដល់បងស្រី ដែលបានអនុញ្ញាតិអោយរូបនាងខ្ញុំសម្ភាសបង។ ចាំបង! ចឹងបងអើអរគុណខ្លាំងមែនទែនណាំបងណាំ។

ខៈ ចាំ!